**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៦ សរណន

# សារាចរណែនាំ

# ស្តីពី

# ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

## I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៧

### ក- *ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច*

១- ឆ្នាំ ២០០៥ គឺជាឆ្នាំទីពីរនៃដំណើរការរបស់រាជរដ្ឋាភិបាលនីតិកាលទី ៣ ហើយក៏ជាឆ្នាំទីពីរនៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី ៣ ជាពិសេស ការដាក់អោយអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** ដើម្បីធានាអោយបាននូវកំណើនសេដ្ឋកិច្ចក្នុងកំរិតខ្ពស់ ប្រកបដោយចិរភាព និង សមធម៌ ដែលជាគន្លឹះដ៏សំខាន់បំផុតសំរាប់សំរេចបានជោគជ័យនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ទន្ទឹមនឹងនេះ វាក៏ជាឆ្នាំនៃការបន្តជំរុញកំណែទំរង់ស៊ីជំរៅលើគ្រប់វិស័យ ជាពិសេស ការកែទំរង់ប្រព័ន្ធច្បាប់ ការកែទំរង់រដ្ឋបាលសាធារណៈ និង ការកែទំរង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

២- ឆ្នាំ ២០០៥ ត្រូវបានចាប់ផ្តើមចេញពីស្ថានភាពប្រកបដោយភាពទុទិដ្ឋិនិយម នោះគឺការប្រឈមនឹងការបញ្ចប់ប្រព័ន្ធកូតា ។ ប្រការនេះបានទាមទារអោយមានការខិតខំកែប្រែរចនាសម្ព័ន្ធនៃមូលដ្ឋានសេដ្ឋកិច្ចពីការប្រមូលផ្តុំការពឹងផ្អែកទៅលើកត្តាខាងក្រៅ ដែលឈរជាសំខាន់លើវិស័យឧស្សាហកម្មកាត់ដេរ និង ទេសចរណ៍ ទៅរកការពង្រីកមូលដ្ឋានសេដ្ឋកិច្ចផ្ទៃក្នុងវិញ ដូចជាការពង្រឹង និង ពង្រីក វិស័យកសិកម្ម វិស័យកសិ-ឧស្សាហកម្ម និង សេវាកម្ម ជាពិសេស ការកសាងប្រព័ន្ធស្រោចស្រព ការបង្កើនផលិតភាពកសិកម្ម និង ការពង្រឹងវិស័យឯកជន តាមរយៈអាជីវកម្មធុនតូច និង មធ្យម ។ ទន្ទឹមនឹងនេះ រាជ-រដ្ឋាភិបាលបានបន្តខិតខំប្រឹងប្រែងអនុវត្តដោយមធ្យ័តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង សារពើពន្ធ ។ ប្រការនេះ បាននាំមកនូវលទ្ធផលដ៏ល្អប្រសើរ ។ ជាក់ស្តែង ក្នុងឆ្នាំ ២០០៥ កំណើនសេដ្ឋកិច្ចគិតតាមថ្លៃថេរសំរេចបាន ១៣,៤% ធៀបនឹងការព្យាករណ៍ប្រមាណ ២-២,៥% នៅដើមឆ្នាំ ។ កំណើននេះ បានមកដោយសារ វិស័យកសិកម្មបានកើនរហូតដល់ ១៧,៣% ដែលក្នុងនោះ ដំណាំស្រូវបានកើនឡើងរហូតដល់

២៧% វិស័យឧស្សាហកម្មបានកើន ១៣,៣% ដែលក្នុងនោះ ផលិតកម្មសំណង់បានកើនឡើង ១៩,២% និង ផលិតកម្មកាត់ដេរបានកើនឡើង ១២,៦% និង វិស័យសេវាកម្មបានកើនឡើងប្រមាណ ៩,៤% ដែលក្នុងនោះ ទេសចរណ៍បានកើនឡើងរហូតដល់ ១៦% ។ ទន្ទឹមនឹងស្ថិរភាពនៃអត្រាប្តូរប្រាក់ អតិផរណាបានកើនឡើងរហូតដល់ប្រមាណជាង ៦% ខ្ពស់ជាងការគ្រោងទុកដើមឆ្នាំ ដោយសារឥទ្ធិពលនៃការឡើងថ្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ ។

៣- ក្នុងឆ្នាំ ២០០៦ នេះ តាមការព្យាករណ៍ចុងក្រោយ កំណើនសេដ្ឋកិច្ចនឹងអាចថយចុះមកនៅត្រឹមប្រមាណ ៥% ធៀបនឹងការព្យាករណ៍ដើមឆ្នាំប្រមាណ ៦,១% ។ នេះជាសេណារីយ៉ូទុទិដ្ឋិនិយមបំផុត ។ តាមសេណារីយ៉ូនេះ កំណើនវិស័យកសិកម្មអាចថយចុះបើធៀបនឹងឆ្នាំ ២០០៥ (តែមានកំណើនប្រមាណ ១៥% បើធៀបនឹងឆ្នាំ ២០០៤) កំណើនផលិតផលស្រូវឆ្នាំនេះ អាចទាបជាងរហូតដល់ប្រមាណ ១០% ធៀបនឹងឆ្នាំ ២០០៥ ។ ដើម្បីជំនះ ទស្សនៈអនាគតដែលមានលក្ខណៈទុទិដ្ឋិនិយមនេះ រាជរដ្ឋាភិបាលបាន និង កំពុងបន្តខិតខំកសាងប្រព័ន្ធស្រោចស្រពបន្ថែមយ៉ាងសកម្ម សំដៅកាត់បន្ថយការពឹងផ្អែកលើធម្មជាតិ ។ បណ្តាឥទ្ធិពលអវិជ្ជមានផ្សេងៗទៀតមកលើកំណើនសេដ្ឋកិច្ចសំរាប់ឆ្នាំ ២០០៦ នេះ រួមមានដូចជា លទ្ធភាពនៃការរីករាលដាលជម្ងឺផ្តាសសាយបក្សី និង ការបន្តកើនឡើងនៃតំលៃប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ។ ទន្ទឹមនឹងនេះ វិស័យឧស្សាហកម្មនឹងកើនប្រមាណ ១១% ដែលក្នុងនោះ ផលិតកម្មសំណង់នឹងកើនប្រមាណ ២០% និង ផលិតកម្មកាត់ដេរនឹងកើនប្រមាណ ១០% និង វិស័យសេវាកម្មនឹងកើនប្រមាណ ៧% ដែលក្នុងនោះ ទេសចរណ៍នឹងកើនឡើងប្រមាណ ៩% ។ រីឯអត្រាអតិផរណានឹងធ្លាក់ចុះមកនៅត្រឹមប្រមាណ ៥% ហើយអត្រាប្តូរប្រាក់នឹងនៅតែរក្សាបានស្ថេរភាពដដែលគឺក្នុងរង្វង់ ៤ ១០០ រៀល ក្នុង ១ ដុល្លារអាមេរិក ។ ទោះជាយ៉ាងណាក៏ដោយ ការព្យាករណ៍សំរាប់រយៈពេលមធ្យម (២០០៧-២០០៩) បង្ហាញអោយឃើញថា មូលដ្ឋានសេដ្ឋកិច្ចនឹងនៅតែអាចរក្សាបាននូវអត្រាកំណើនជាមធ្យមប្រមាណពី ៦% ទៅ ៧% ស្របតាមគោលដៅនៃយុទ្ធសាស្ត្រចតុកោណ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ទុនបំរុងសំរាប់ធានាការនាំចូលនឹងត្រូវបានរក្សាក្នុងរង្វង់ពី ២,៥ -៣ ខែ ដដែល ។

## ខ- ស្ថានភាពសារពើពន្ធ និង ថវិកា

៤- ការអនុវត្តន៍គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និង គោលនយោបាយសារពើពន្ធប្រកបដោយភាពប្រុងប្រយ័ត្ន គួបផ្សំនឹងការអនុវត្តន៍កម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈយ៉ាងមោះមុត គ្រប់ជ្រុងជ្រោយ និង ជាជំហានៗយ៉ាងច្បាស់លាស់ បានធ្វើអោយការអនុវត្តន៍គោលនយោបាយសារពើពន្ធ និង ការអនុវត្តន៍ថវិកាឆ្នាំ ២០០៥ សំរេចបានលទ្ធផលយ៉ាងល្អប្រសើរគួរជាទីមោទនៈ ។ ជាក់ស្តែង ចំណូលក្នុងស្រុកសរុបសំរេចបាន ១១៤,៧% គឺមានកំនើន ២២,៨% ធៀបនឹងឆ្នាំ ២០០៤ ហើយស្មើនឹង ១០,៦៧% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធសំរេចបាន ១១០,៥% ស្មើនឹង ៧,៨% នៃផសស មានកំណើន ២០,៤% ធៀបនឹងឆ្នាំ ២០០៤ និង ចំណូលមិនមែនសារពើពន្ធសំរេចបាន ១០៤,៥% ស្មើនឹង ២,២៧% នៃផសស មានកំណើន ៦,៦% ធៀបនឹងឆ្នាំ ២០០៤ ។ រីឯការអនុវត្តន៍ចំណាយវិញក៏មានលក្ខណៈល្អប្រសើរផងដែរ ជាក់ស្តែង ចំណាយសរុបឆ្លងកាត់រតនាគារអនុវត្តបាន ៩៩,២% មានកំនើន ១២,១% បើធៀបនឹងឆ្នាំ ២០០៤

ស្មើនឹង ៩,៦៩% នៃផសស ដែលក្នុងនោះចំណាយចរន្តអនុវត្តន៍បាន ១០០,២% មានកំណើន ១០% និង ចំណាយមូលធនអនុវត្តន៍បាន ១៣០,៥% មានកំណើន ២២,៧% ។ ទន្ទឹមនឹងនេះ ចំណាយតាមវិស័យដែលអនុវត្តបានគឺវិស័យរដ្ឋបាលទូទៅសំរេចបាន ១២៨,២% កើនឡើង ១៧,៨% ធៀបនឹងឆ្នាំ ២០០៤ ស្មើនឹង ១,៤% នៃផសស វិស័យសន្តិសុខ និង យោធាសំរេចបាន ៩៩,៨% កើនឡើង ៦,៧% ធៀបនឹងឆ្នាំ ២០០៤ ស្មើនឹង ១,៧៧% នៃផសស វិស័យសេដ្ឋកិច្ចសំរេចបាន ៨៩% កើនឡើង ១៧,៨% ស្មើនឹង ០,៧០% នៃផសស និង វិស័យសង្គមកិច្ចសំរេចបាន ៩៥,៧% កើនឡើង ៨,៦% ធៀបនឹងឆ្នាំ ២០០៤ ស្មើនឹង ២,៨៦% នៃផសស ។ លទ្ធផលនៃការអនុវត្តន៍ចំណូល និង ចំណាយនេះ បានធ្វើអោយមានអតិរេកចរន្តស្មើនឹង ២% និង ឱនភាពថវិកាសរុបស្មើនឹង ២,៩៩% នៃផសស ។

៥- ទោះជាកំណើនសេដ្ឋកិច្ចឆ្នាំ ២០០៦ អាចថយចុះច្រើនធៀបនឹងឆ្នាំ ២០០៥ ក៏ដោយ ក៏យើងសង្ឃឹមថានឹងមិនមានឥទ្ធិពលជាអវិជ្ជមានធ្ងន់ធ្ងរមកលើស្ថានភាពសារពើពន្ធ និង ពិសេសលើការអនុវត្តន៍ថវិកាឡើយ ព្រោះបំរែបំរួលឡើងចុះនៃផសស ពីមួយឆ្នាំទៅមួយឆ្នាំ អាស្រ័យជាសំខាន់ទៅលើវិស័យកសិកម្មជាពិសេស ចំពោះដំណាំស្រូវ (ដោយសារវិស័យនេះនៅពឹងផ្អែកខ្លាំងនៅឡើយទៅលើកត្តាអាកាសធាតុ) ដែលពុំមែនជាមូលដ្ឋាននៃការប្រមូលចំណូលទេ លើកលែងតែមានគ្រោះទឹកជំនន់ ឬ គ្រោះរាំងស្ងួតដែលអាចនឹងតំរូវអោយមានចំណាយបន្ថែមឥតគ្រោងទុកកើនឡើង ។ ចំណូលក្នុងស្រុកសរុបអាចនឹងសំរេចបាន ១០,៩% នៃផសស កើនឡើងប្រមាណ ០,២% នៃផសស ធៀបនឹងឆ្នាំ ២០០៥ ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសំរេចបាន ៨,៣% នៃផសស កើនប្រមាណ ០,៥% នៃផសស ចំណូលមិនមែនសារពើពន្ធនឹងសំរេចបាន ២,២% នៃផសស ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៥ និង ចំណូលមូលធននឹង សំរេចបាន ០,៤% ។ ចំណាយសរុបអាចនឹងសំរេចបាន ១៤,៩% នៃផសស កើនឡើង ១,២% នៃផសស ធៀបនឹងឆ្នាំ ២០០៥ ដែលក្នុងនោះ ចំណាយចរន្តនឹងសំរេចបាន ៩,៣% នៃផសស កើនឡើង ១,២% នៃ ផសស ធៀបនឹងឆ្នាំ ២០០៥ និង ចំណាយមូលធនអាចនឹងសំរេចបាន ៥,៧% នៃផសស កើនឡើង ០,១% នៃ ផសស ធៀបនឹងឆ្នាំ ២០០៥ ។ ការអនុវត្តន៍ចំណូល និង ចំណាយនេះ អាចនឹងធ្វើអោយមានអតិរេកចរន្តប្រមាណ ១,២% និង ឱនភាពថវិកាសរុបប្រមាណ ៤% នៃផសស ។

៦- ដោយសារការពង្រឹង និង បង្កើនសមត្ថភាព និង ប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូល និង ចំណាយក្នុងក្របខ័ណ្ឌ **កម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ** ការអនុវត្តន៍ចំណូល និង ចំណាយឆ្នាំ ២០០៦ សង្ឃឹមថានឹងទទួលបានលទ្ធផលល្អប្រសើរជាងឆ្នាំ ២០០៥ បន្ថែមទៀត ។ ជាក់ស្តែង លទ្ធផលនៃការអនុវត្តន៍ត្រីមាសទី១ បានបង្ហាញអោយឃើញថា ចំណូលក្នុងស្រុកសរុបអនុវត្តបាន ២១% នៃផែនការឆ្នាំ មានកំណើនប្រមាណ ៨% ធៀបនឹងឆ្នាំ ២០០៥ ដែលក្នុងនោះចំណូលគយ និង រដ្ឋាករ សំរេចបាន ២០% មានកំណើនប្រមាណ ២,៥% ធៀបនឹងឆ្នាំ ២០០៥ ពន្ធដារសំរេចបាន ៣០% មានកំណើន ១៥,៦% ធៀបនឹងឆ្នាំ ២០០៥ និង ចំណូលមិនមែនសារពើពន្ធសំរេចបាន ១៨% មានកំណើន ១២,៨% ធៀបនឹងឆ្នាំ ២០០៥ ។ នៅក្នុងឆ្នាំនេះ រាជរដ្ឋាភិបាលបានទទួលការលុបបំណុលប្រមាណ ៨២ លានដុល្លារអាមេរិក ពីមូលនិធិរូបិយវត្ថុអន្តរជាតិហើយថវិកានេះគ្រោងនឹងផ្ទេរប្រមាណ ២៧ ពាន់លានរៀល ចូលទៅក្នុងថវិការដ្ឋឆ្នាំ ២០០៦ ដើម្បីបង្កើនចំណាយ

លើការវិនិយោគដែលជាមុខព្រួញសំរាប់ការកាត់បន្ថយភាពក្រីក្រ ។ ប្រការនេះ ក៏នឹងជួយសំរួលអោយរាជរដ្ឋាភិបាលអាចផ្ទេរធនធានមួយចំនួនរបស់ខ្លួន មកទប់ទល់កំណើននៃចំណាយលើការទូទាត់សងការប្រាក់លើកម្ចីបរទេស ជាពិសេស នៅពេលដែលការចរចាបំណុលជាមួយសហរដ្ឋអាមេរិក និង រុស្ស៊ី ត្រូវបានបញ្ចប់ ។

## II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និង ថវិកាឆ្នាំ ២០០៧

### ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៧- ឆ្នាំ ២០០៧ គឺជាឆ្នាំទី ២ នៃការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** និង ជាឆ្នាំទី ៣ នៃការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាល ជាពិសេស ការបន្តរក្សាអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ពី ៦ ទៅ ៧ ភាគរយ ប្រកបដោយចិរភាព និង បន្តរក្សាបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគន្លឹះ និង ចាំបាច់បំផុតក្នុងការឈានទៅសំរេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាល គឺការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ទន្ទឹមនឹងនេះ វាក៏ជាឆ្នាំដែលត្រូវបន្តការធ្វើកំណែទំរង់ស៊ីជំរៅលើគ្រប់វិស័យ ជាពិសេស កំណែទំរង់ហិរញ្ញវត្ថុសាធារណៈ កំណែទំរង់សំដៅអភិវឌ្ឍន៍វិស័យឯកជន កំណែទំរង់ច្បាប់ ប្រព័ន្ធតុលាការ ការគ្រប់គ្រងដីធ្លី ការលើកស្ទួយវិស័យកសិកម្ម កសិ-ឧស្សាហកម្ម និង សហគ្រាសធុនតូច និង មធ្យម ក្នុងគោលដៅធ្វើពិពិធកម្មសេដ្ឋកិច្ច ។

៨- ឆ្នាំ ២០០៧ អាចនិយាយបានថា គឺជាឆ្នាំដែលមូលដ្ឋានសេដ្ឋកិច្ចកម្ពុជាបានឈានមកដល់ចំណុចរបត់នៃការវិវិលទៅរកដំណាក់កាលនៃការអភិវឌ្ឍន៍មួយខ្ពស់ជាងមុន ដែលទាមទារអោយមានការពង្រីកមូលដ្ឋាននៃកំណើន តាមរយៈការលើកស្ទួយវិស័យកសិកម្ម និង ការពង្រឹងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និង សេវាកម្ម ដើម្បីបង្កើនតំលៃបន្ថែមលើផលិតកម្ម និង ស្រូបយកកំលាំងពលកម្មដែលចេះតែបន្តផ្ទេរមកពីវិស័យកសិកម្ម ។ ធ្វើយ៉ាងនេះ ទើបអាចរក្សាបាននូវចិរភាព និង សមធម៌នៃកំណើនសេដ្ឋកិច្ចបាន ។ ដូច្នេះ នៅក្នុងរយៈពេលមធ្យម (២០០៧-២០១១) កំណើនសេដ្ឋកិច្ចកម្ពុជានឹងបន្តកើនឡើង ក៏ប៉ុន្តែនឹងកើនក្នុងល្បឿនមួយយឺតជាងមុន ហើយល្បឿននេះអាស្រ័យដោយល្បឿននៃការបង្កើនផលិតភាពកសិកម្ម និង ការពង្រីក និង ពង្រឹងវិស័យឧស្សាហកម្ម ពាណិជ្ជកម្ម និង សេវាកម្ម ។ ទោះជាយ៉ាងណាក៏ដោយ មូលដ្ឋានសេដ្ឋកិច្ចនឹងនៅតែអាចរក្សាកំណើនជាមធ្យមប្រមាណពី ៦% ទៅ ៧% នៅក្នុងរយៈពេលមធ្យមនេះ ។ តាមការព្យាករណ៍ដែលមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០០៧ ខាងមុខនេះ អាចនឹងសំរេចបានប្រហែល ៦,៥% ដោយសារវិស័យកសិកម្មនឹងកើនឡើង ៤% ដែលក្នុងនោះ ផលិតផលស្រូវនឹងកើនឡើងប្រមាណ ៤% វិស័យឧស្សាហកម្មនឹងកើនឡើង ៨% ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌនឹងកើនឡើងប្រមាណ ៩% និង ផលិតផលសំណង់នឹងកើនឡើង ៨% និង វិស័យសេវាកម្មនឹងកើនឡើង ៦,៥% ដែលក្នុងនោះ ទេសចរណ៍នឹងកើនឡើងប្រមាណ ៨% ។

### *ខ- ក្របខ័ណ្ឌគោលនយោបាយសារពើពន្ធ និង ថវិកា*

៩- ដោយឈរលើមូលដ្ឋាននៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ជាពិសេស **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** **យុទ្ធសាស្ត្រចតុកោណ** និង គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ថវិកាឆ្នាំ ២០០៧ មានគោលដៅសំខាន់ៗដូចតទៅ ÷

- ធានាអោយបាននូវការអនុវត្តន៍គោលនយោបាយអាទិភាពតាមវិស័យ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេស គោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន
- ធានាការបន្តអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាល
- ធានាបំរើអោយការបន្តសកម្មភាពកែទំរង់ស៊ីជំរៅរបស់រាជរដ្ឋាភិបាល លើគ្រប់មុខសញ្ញា ដូចជា កំណែទំរង់ហិរញ្ញវត្ថុសាធារណៈ កំណែទំរង់អភិវឌ្ឍន៍វិស័យឯកជន កំណែទំរង់ប្រព័ន្ធច្បាប់ និង តុលាការ កំណែទំរង់វិស័យកងទ័ព កំណែទំរង់វិស័យរដ្ឋបាលសាធារណៈ និង ការពង្រឹងអភិបាលកិច្ចល្អ
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈដែលមានលក្ខណៈរំកិល ៣ ឆ្នាំ (Public Investment Program, PIP)
- ធានាបំរើអោយការរៀបចំបោះឆ្នោតឃុំ- សង្កាត់ ដើម្បីបន្តពង្រឹងយន្តការលទ្ធិប្រជាធិបតេយ្យ និង ការបន្តពង្រឹងសមត្ថភាពរដ្ឋបាល បច្ចេកទេស និង ហិរញ្ញវត្ថុក្រុមប្រឹក្សាឃុំ- សង្កាត់ សំរាប់ការអភិវឌ្ឍន៍មូលដ្ឋាន
- ធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សេវាកម្មនៅក្នុងវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំ និង សុខាភិបាល
- ធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់សកម្មភាពដែលបំរើអោយវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការអភិវឌ្ឍន៍ជនបទ និង ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ។

១០- ដើម្បីសំរេចបានតាមគោលដៅនៃគោលនយោបាយខាងលើ រាជរដ្ឋាភិបាលត្រូវអនុវត្តទៅតាមក្របខ័ណ្ឌយុទ្ធសាស្ត្រសារពើពន្ធ និង ថវិកា ជាពិសេសការបន្តប្រមូលផ្តុំជំរុញការអនុវត្តន៍កម្មវិធីកែទំរង់សំខាន់ៗដូចខាងក្រោម៖

*ក.* បន្តអនុវត្តនូវគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចត្រឹមត្រូវ និង ប្រុងប្រយ័ត្ន ដើម្បីជាបរិស្ថានសំរាប់សំរេចអោយបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ និង ប្រកបដោយចិរភាពក្នុងបរិការណ៍នៃអត្រាអតិផរណាទាប ។

*ខ.* បន្តអនុវត្តនូវកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការសំរេចអោយបាននូវគោលដៅនៃជំហានទី១ គឺការធានាការជឿទុកចិត្តបាននៃថវិកា តាមរយៈការកាត់បន្ថយនិតិវិធីចំណាយ ការរក្សាស្ថេរភាព និង និរន្តរភាពចំណូល ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវា និង វិធានការកាត់បន្ថយបំណុលសាច់ប្រាក់ដែលរដ្ឋជំពាក់អ្នកផ្គត់ផ្គង់ឯកជន និង ការចាប់ផ្តើមអនុវត្តប្លង់

គណនេយ្យថ្មី និង មាតិកាថវិកាថ្មី និង ការសាកល្បងអនុវត្តថវិកាតាមកម្មវិធី ដែលជាមូលដ្ឋានសំរាប់ការឈានទៅបណ្តាជំហានទី ២ និង ទី ៣ ។ ទន្ទឹមនឹងនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំធ្វើវិសោធនកម្មច្បាប់ប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ ១៩៩៣ និង ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត- ក្រុងឆ្នាំ ១៩៩៨ លើមាត្រាមួយចំនួនដើម្បីអនុវត្តប្លង់គណនេយ្យថ្មី និង មាតិកាថវិកាថ្មី ដោយដាក់បញ្ចូលទៅក្នុងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ តែម្តង ។ ដោយឡែក នៅក្នុងឆ្នាំ ២០០៧ ខាងមុខនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ ១៩៩៣ និង ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត- ក្រុងឆ្នាំ ១៩៩៨ ទាំងមូលតែម្តង ដោយធ្វើការកែប្រែទាំងរចនាសម្ព័ន្ធនៃច្បាប់ ទាំងការលុបមាត្រាចាស់ និង បន្ថែមមាត្រាថ្មី ដើម្បីអោយស្របទៅនឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈថ្មី ដែលបាន និង កំពុងកសាង និង ដាក់អោយអនុវត្តដោយផ្នែកៗ និង ជាបណ្តើរៗ ក្រោមកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីចាប់ផ្តើមអនុវត្តពីឆ្នាំ ២០០៨ តទៅ ។

*គ.* បន្តអនុវត្តកំណែទម្រង់រចនាសម្ព័ន្ធ ដើម្បីពង្រឹងបរិស្ថានអំណោយផលសម្រាប់ការអភិវឌ្ឍន៍ផ្នែកឯកជន ជាពិសេសលើកស្ទួយវិស័យកសិកម្ម និង កសិ- ឧស្សាហកម្ម និង ជួយគាំទ្រសហគ្រាសធុនតូច និង មធ្យម ព្រមទាំងជំរុញការសំរួលពាណិជ្ជកម្មតាមរយៈការបង្កើតបញ្ជរតែមួយ និង ជំរុញផ្នែកឯកជនអោយចូលរួមកសាងហេដ្ឋារចនាសម្ព័ន្ធ ដោយមានច្បាប់សម្បទានធានា ក្នុងខណៈដែលរាជរដ្ឋាភិបាលខ្លួនឯងបាន និង កំពុងខិតខំកសាងដោយផ្ទាល់នូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសប្រព័ន្ធស្រោចស្រព ។ ប្រការទាំងនេះទាមទារការពង្រឹងអភិបាលកិច្ចល្អ ពិសេសវិធានការណ៍ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តន៍កម្មវិធីសកម្មភាពកំណែទំរង់ច្បាប់ និង ប្រព័ន្ធតុលាការ ការពង្រឹងនីតិរដ្ឋ និង ការពង្រឹងទីផ្សារពលកម្ម ។

*ឃ.* បន្តអនុវត្តនូវកំណែទម្រង់ការគ្រប់គ្រងដីធ្លី ដើម្បីជួយគាំទ្រដល់វិស័យកសិកម្មអោយសមស្របតាមច្បាប់ភូមិបាល ដើម្បីឱ្យវិស័យនេះក្លាយទៅជាមូលដ្ឋានរឹងមាំនៃកំណើនសេដ្ឋកិច្ច និង បំរើគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ។

*ង.* បន្តពង្រឹងប្រព័ន្ធធនាគារ និង វិស័យធានារ៉ាប់រង និង បន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីកៀងគរធនធានហិរញ្ញវត្ថុសម្រាប់ការធ្វើហិរញ្ញប្បទានគម្រោងរបស់ផ្នែកឯកជន ។

*ច.* កសាង និង ពង្រឹងការអនុវត្តន៍ច្បាប់ និង លិខិតបទដ្ឋាននានា ជាពិសេសពង្រឹងរចនាសម្ព័ន្ធស្ថាប័ន និង បំពេញកាតព្វកិច្ចកម្ពុជា ក្នុងឋានៈជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក ដើម្បីទាញប្រយោជន៍ពីសមាជិកភាពនេះអោយបានជាអតិបរមា ។

*ឆ.* បន្តជម្រុញអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ពិសេសធានាពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និង ហិរញ្ញវត្ថុ របស់ក្រុមប្រឹក្សាឃុំ- សង្កាត់ សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន និង ពង្រីកមូលដ្ឋាននៃការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ ពិសេសគឺដើម្បីបម្រើឱ្យគោលការណ៍ «រដ្ឋបាលឯកភាព» ដូចមានកំណត់នៅក្នុងឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ ។ ក្នុងកម្មវិធីនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវរៀបចំ និង អនុវត្តផែនការបង្កើនប្រសិទ្ធភាពនៃការផ្ទេរ និង ការផ្តល់ថវិកាជូនមូលនិធិឃុំ- សង្កាត់ រួមមានទាំងលទ្ធភាពនៃការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារផងដែរ ។ លើសពីនេះទៀត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវសិក្សាដើម្បីដាក់ឱ្យអនុវត្តសាកល្បងនូវការប្រមូល

ចំណូលផ្ទាល់ដោយក្រុមប្រឹក្សាឃុំ- សង្កាត់ ជាពិសេសគឺពន្ធប៉ាតង់ និង ពន្ធលើមធ្យោបាយដឹកជញ្ជូននៅរាជធានីភ្នំពេញ និង នៅក្រុងព្រះសីហនុ តែត្រូវស្ថិតក្នុងក្របខ័ណ្ឌច្បាប់ស្ដីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត- ក្រុង ។

*៥.* បន្តជម្រុញការអនុវត្តន៍កំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការពង្រីកការអនុវត្តន៍កម្មវិធីអាទិភាព ជាពិសេស កម្មវិធីផ្ដល់លាភការទៅតាមសមត្ថភាព និង លទ្ធផលការងារ និង ការវិភាគមុខងារ ដើម្បីបង្កើនផលិតភាព និង ប្រសិទ្ធភាពការងារ ។

## III. ការគណនា និង ទិសដៅថវិកាជាតិឆ្នាំ ២០០៧

### ក- គំរោងចំណាយថវិកា

**១១-** ដើម្បីធានាបាននូវការអនុវត្តន៍ទៅតាមគោលដៅទាំងអស់ខាងលើ និង ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង សារពើពន្ធដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០០៧ ត្រូវគ្រោងឡើងលើមូលដ្ឋានយុទ្ធសាស្ត្រ និង វិធានការដូចខាងក្រោម៖

- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបអោយស្ថិតនៅក្នុងកំរិត ១៦% នៃផសស គឺកើនឡើងប្រមាណ ១% នៃផសស ដែលក្នុងនោះ ចំណាយចរន្តសរុបនឹងត្រូវបានរក្សាអោយនៅត្រឹមប្រមាណ ១០% នៃផសស និង ចំណាយមូលធននឹងត្រូវបានរក្សានៅត្រឹមប្រមាណ ៦% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់ ១,៤% នៃផសស និង ឱនភាពថវិកាសរុបក្នុងរង្វង់ ៤% នៃផសស ។ ដោយឡែក ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងចំនួន ១,៩% នៃផសស ហើយចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវកំណត់ក្នុងចំនួន ៣,៦% នៃផសស ។ ទន្ទឹមនឹងនេះ បង្កើនចំណាយសំរាប់រំលស់បំណុលដល់ចំនួន ០,៥% នៃផសស ។
- ត្រូវបែងចែកចំណាយចរន្តទៅតាមវិស័យនីមួយៗដូចតទៅៈ រដ្ឋបាលទូទៅ ១,៤% នៃផសស ផ្នែកសន្តិសុខ និង យោធា ១,៧% នៃផសស វិស័យសេដ្ឋកិច្ច ១% នៃផសស សង្គមកិច្ចស្មើនឹង ៣,៥% នៃផសស និង ថវិកាផ្ទាល់របស់ខេត្ត- ក្រុងប្រមាណ ០,៤% នៃផសស ។

**១២-** ថវិកាឆ្នាំ ២០០៧ ខាងមុខនេះ ត្រូវបំរើគោលនយោបាយរាជរដ្ឋាភិបាល ក្នុងវិស័យសេដ្ឋកិច្ច និង សង្គមកិច្ច និង ការលើកស្ទួយជីវភាពនៅទីជនបទ សំដៅសំរេចនូវការអភិវឌ្ឍន៍ប្រកបដោយចីរភាព និង ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ថវិកាឆ្នាំ ២០០៧ នឹងផ្ដល់ការបែងចែកជាក់ស្ដែងទៅតាមវិស័យជាអាទិភាពទាំងនេះដូចខាងក្រោម៖

- បង្កើនថវិកាសំរាប់វិស័យសុខាភិបាលអោយដល់ ១០,៩% នៃចំណាយចរន្តថវិការដ្ឋ គឺកើន ០,១% ធៀបទៅនឹងថវិកាឆ្នាំ ២០០៦ ដើម្បីសំរេចបាន ១,០៥% នៃផសស គឺកើន ០,១៥% ធៀបនឹងឆ្នាំ ២០០៦ ស្របតាមការកំណត់នៃគម្រោងកម្មវិធីចំណាយរយៈពេលមធ្យមសំរាប់វិស័យសុខាភិបាលឆ្នាំ ២០០៧ ។

• បង្កើនថវិកាសំរាប់វិស័យអប់រំអោយដល់ ១៨,៤% នៃចំណាយចរន្តថវិការដ្ឋ គឺកើន ០,១% ធៀបទៅនឹងថវិកាឆ្នាំ ២០០៦ ដើម្បីសម្រេចបាន ១,៧៦% នៃផសស គឺកើន ០,១៦% ធៀបនឹងឆ្នាំ ២០០៦ ស្របតាមការកំណត់នៃគម្រោងកម្មវិធីចំណាយរយៈពេលមធ្យមសំរាប់វិស័យអប់រំឆ្នាំ ២០០៧ ។

• បង្កើនថវិកាសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រព ការអភិវឌ្ឍន៍កសិកម្ម និង ការអភិវឌ្ឍន៍ជនបទអោយដល់ ៤,៧% នៃចំណាយចរន្តថវិការដ្ឋ គឺកើន ០,១% ធៀបទៅនឹងថវិកាឆ្នាំ ២០០៦ ដើម្បីសម្រេចបាន ០,៤៥% នៃផសស គឺកើន ០,០៥% ធៀបនឹងឆ្នាំ ២០០៦ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញវិស័យសេដ្ឋកិច្ច ដើម្បីកំណើន និង កាត់បន្ថយភាពក្រីក្រ ។

• បង្កើនមូលនិធិថវិកាឃុំ- សង្កាត់ឆ្នាំ ២០០៧ ឱ្យដល់ ៨៥ ពាន់លានរៀល (២.៥៤% នៃចំណូលចរន្តថវិការដ្ឋ) ។

• បន្តផ្តល់អាទិភាព និង ជំរុញការរៀបចំថវិកាតាមកម្មវិធី និង ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដើម្បីបង្កើនប្រសិទ្ធភាពថវិកា និង ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ជាពិសេស ការដាក់អោយអនុវត្តសាកល្បងនូវការរៀបចំ និង អនុវត្តថវិកាតាមកម្មវិធីតាមរយៈការកែលំអកម្មវិធីសកម្មភាពជាអាទិភាព និង ការសាកល្បងអនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម នៅក្រសួងចំនួន ៧ គឺ ក្រសួងអប់រំ យុវជន និង កីឡា ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងយុត្តិធម៌ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង ក្រសួងកិច្ចការនារី ។

• បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស ការកែលំអការអនុវត្តន៍ថវិកា តាមរយៈការកាត់បន្ថយនិតិវិធីចំណាយ ការពង្រឹងនិតិវិធី និង ធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និង ការកែលំអការរៀបចំថវិកា តាមរយៈការកែលំអវិធីសាស្ត្រនៃការរៀបចំថវិកា ព្រមទាំងការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដើម្បីសំរេចបានតាមគោលដៅជំហានទី១ គឺការបង្កើនភាពជឿទុកចិត្តបាននៃថវិកា និង ការចាប់ផ្តើមជំហានទី២ គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ តាមរយៈការដាក់អោយអនុវត្តនូវប្លង់គណនេយ្យ និង មាតិកាថវិកាថ្មី នៅក្នុងក្របខ័ណ្ឌកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ។

**ខ- គំរោងចំណូលថវិកា**

**១៣-** ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃគំរោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការអនុវត្តន៍អោយបានសំរេចទៅតាមផែនការសកម្មភាព និង គោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទំរង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសំរេចអោយបាននូវកំរិតចំណូលក្នុងស្រុកសរុបប្រមាណ ១១,៩៥% នៃផសស គឺមានកំណើន ១,៦% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ដែលក្នុងនោះ ចំណូលសារពើពន្ធត្រូវសំរេចអោយបាន ៨,៨% នៃផសស គឺមានកំណើន ០,៩% នៃផសស ធៀបនឹងឆ្នាំ ២០០៦ ចំណូលមិនមែនសារពើពន្ធត្រូវសំរេចអោយបាន ២,៦៣% នៃផសស គឺមានកំណើន ០,៤% ធៀបនឹងឆ្នាំ ២០០៦ និង ចំណូលមូលធនក្នុងស្រុកត្រូវសំរេច

អោយបាន ០,៥៣% នៃផសស គឺមានកំណើន ០,២៨% ធៀបនឹងឆ្នាំ ២០០៦ (៨៥ ពាន់លានរៀល បានមកពីធនាគារជាតិ លើការផ្ទេរបំណុលដែលបានលើកលែងដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ) ។

១៤- ដើម្បីសំរេចបានតាមគោលដៅនៃការប្រមូលចំណូលសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៧ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តអនុវត្តបណ្តាវិធានការហ្មឺងម៉ាត់ទាំងឡាយ នៅក្នុងកម្មវិធីសកម្មភាពកែទំរង់ការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតទៅលើបណ្តាវិធានការសំខាន់ៗមួយចំនួនដូចខាងក្រោម ÷

**ទី១- ផ្នែកចំណូលពន្ធដារ:**

- បន្តការពង្រឹង និង កែលំអរដ្ឋបាលពន្ធដារ ការធ្វើសវនកម្មពន្ធ ការពង្រីកមូលដ្ឋានយកពន្ធ ការបង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និង ការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត ។
- បន្តអនុវត្តនូវកម្មវិធីកែលំអរចនាសម្ព័ន្ធ តាមរយៈការអនុវត្តន៍នូវប្រព័ន្ធគ្រប់គ្រងតាមបែបអន្តរជាតិចំពោះរាល់តួនាទី ភារកិច្ច និង ប្រតិបត្តិការរបស់នាយកដ្ឋានពន្ធដារ ។
- កសាង និង អនុវត្ត នូវផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាពត៌មាន ជាពិសេសខាងផ្នែកប្រមូលពន្ធ ការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និង ការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។
- អនុវត្តទាំងស្រុង និង ឱ្យបានហ្មឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង វិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។
- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីករបបពិតនៅតាមបណ្តាខេត្ត- ក្រុងផ្សេងទៀត និង បន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។
- បន្តបណ្តុះបណ្តាល និង បង្កើនសមត្ថភាពវិជ្ជាជីវៈ និង សីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និង មធ្យម ។
- ពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេងកាត ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលជាអតិ-បរិមាពីវិស័យនេះ តាមរយៈការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ។
- ធ្វើការសិក្សាអំពីវិចារណកម្មបន្ត និង លទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និង បណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។
- បន្តពង្រឹងអភិបាលកិច្ចរបស់នាយកដ្ឋានពន្ធដារ ។

**ទី២- ផ្នែកចំណូលពន្ធគយ:**

- បន្តជំរុញការអនុម័តច្បាប់គយ និង ត្រៀមរៀបចំឱ្យបានចប់សព្វគ្រប់នូវលិខិតបទដ្ឋានសំរាប់អនុវត្តច្បាប់នេះ ។
- បន្តកែលំអនិតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ- ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុម-ហ៊ុននាំចេញ- ចូល និង ក្រុមហ៊ុនជើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និង ភាពងាយស្រួល ក្នុងការត្រួតពិនិត្យ និង ក្នុងការយកពន្ធ និង អាករផ្សេងៗ ។
- ចាប់ផ្តើមអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់ទីចាត់ការគយ និង រដ្ឋាករ ។

- អនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយរួមមាន៖

*ក.* វិធានការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ដោយសហការយ៉ាងជិតស្និទជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល និង អាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើ រត់ពន្ធត្រូវតែបង្ហាញឱ្យកាន់តែខ្លាំងក្លាឡើងថែមទៀត នូវវភាពនៃការងាររបស់ខ្លួនក្នុងការទប់ស្កាត់ និង បង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងការអនុវត្តន៍ភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ជាពិសេស លើវិធានការកែលំអផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធ ដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេទយិកភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារអេឡិចត្រូនិច និង ការដាក់ចេញនូវនិតិវិធីត្រួតពិនិត្យថ្មី ។

*ខ.* សហការជាមួយនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និង ផ្លាស់ប្តូរពត៌មាន រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និង កាតព្វកិច្ចពន្ធដារ ។

*គ.* លើកឡើង និង អនុវត្តនូវវិធានការច្បាស់លាស់ តែទន់ភ្លន់ លើមុខទំនិញមួយចំនួន ដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និង រដ្ឋាករ មានជាអាទិ៍ៈ បន្តការបណ្តុះបណ្តាល និង ការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និង សីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និង រដ្ឋបាលគយ ឱ្យបានរឹងមាំ ។

- បន្តការពង្រឹង និង កែលំអរដ្ឋបាលគយ តាមរយៈការធ្វើស្វ័យប្រវត្តិកម្មនិតិវិធីគយ ដើម្បីកែលំអប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និង លើកកំពស់គុណភាពសេវាកម្មជូនដល់អតិថិជន ពិសេសគឺត្រូវរៀបចំឱ្យបានសម្រេច ហើយដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធបញ្ចរតែមួយ (Single Window) សម្រាប់ត្រួតពិនិត្យការនាំចេញ និង នាំចូល នៅតាមច្រកព្រំដែនមួយចំនួន ពិសេស ត្រូវចាប់ផ្តើមនៅកំពង់ផែក្រុងព្រះសីហនុ ។

- ពង្រឹងយន្តការអធិការកិច្ចមុនពេលផ្ទុក ការត្រួតពិនិត្យទំនិញ ការត្រួតពិនិត្យនាវាឆ្លងកាត់ ការបញ្ជូនទំនិញ ការធ្វើអធិការកិច្ចនៅនឹងកន្លែង និង ការប្រមូលចំណូល ។

- បន្តពង្រឹងអភិបាលកិច្ចរបស់រដ្ឋបាលគយ និង រដ្ឋាករ ។

**ទី៣- <u>ចំណូលមិនមែនសារពើពន្ធ:</u>**

- អនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និង លិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រី លេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- កំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធចំណូលមិនមែនសារពើពន្ធ ហើយដាក់ចេញនូវផែនការសកម្មភាពជាក់លាក់ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និង ទូរគមនាគមន៍ អាកាសចរណ៍ស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និង ចំណូលពីការជួលរោងចក្រសហគ្រាស និង ទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តជំរុញការរៀបចំបទបញ្ជារបស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធឱ្យបានរួចរាល់ និង ការរៀបចំអនុក្រឹត្យដែលពាក់ព័ន្ធ ដើម្បីអនុវត្តបទបញ្ជានេះឱ្យមានប្រសិទ្ធភាព ។

- បញ្ចប់ការងារផ្ទេរបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ លើកលែងតែសារពើភ័ណ្ឌដីរដ្ឋ ដែលត្រូវបន្តអនុវត្តនៅក្នុងរយៈពេលវែងខាងមុខ ។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និង ទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និង ផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

១៥- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ២០០៧ នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសំរាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និង ពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ជាមួយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ចាប់ពីថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០០៦ នេះតទៅ រហូតដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៦ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និង ធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះហើយផ្ញើជូនគណៈរដ្ឋមន្ត្រីអោយបាននៅក្នុងសប្តាហ៍ទី១ នៃខែតុលា ឆ្នាំ ២០០៦ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និង សំរេច ហើយផ្ញើជូនរដ្ឋសភាអោយបានក្នុងសប្តាហ៍ទី១ នៃខែ វិច្ឆិកា ២០០៦ ដើម្បីស្ថាប័ននីតិបញ្ញត្តិមានពេលគ្រប់គ្រាន់ ក្នុងការពិនិត្យ ពិភាក្សា និង អនុម័តសេចក្តីព្រាងច្បាប់នេះអោយបានមុនថ្ងៃ ២៥ ខែ ធ្នូ ២០០៦ ។

## គ- បណ្តាបញ្ហាប្រឈមមុខក្នុងការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧

១៦- បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងតែប្រឈមមុខនឹងបញ្ហាមួយចំនួន នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ភាពចាំបាច់ក្នុងការបង្កើនចំណូលដើម្បីសងបំណុលចាស់ផង និង ដើម្បីបំពេញតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់ផង ។ បញ្ហាប្រឈមទាំងអស់នោះ រួមមានដូចខាងក្រោម ÷

*ទី១-* ការធានាអោយបាននូវការគោរពវិន័យថវិកាយ៉ាងខ្ជាប់ខ្ជួន តាមរយៈការពង្រឹងការរៀបចំថវិកាអោយបានគ្រប់ជ្រុងជ្រោយ និង សុក្រឹត ដើម្បីកាត់បន្ថយជាអតិបរិមានូវចំណាយមិនបានគ្រោងទុក និង សំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និង ចំណាយដែលមិនចាំបាច់ ដើម្បី សម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយប្រសិទ្ធភាព និង ប្រកបដោយភាពជឿទុកចិត្តបាន ។

*ទី២-* ការរៀបចំកម្មវិធីចំណូល-ចំណាយអោយបានសុក្រឹត និង ការអនុវត្តន៍អោយបានហ្មឺងម៉ាត់ ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីកាត់បន្ថយបំណុលសាច់ប្រាក់កកស្ទះនៅរតនាគារ ក្នុងគោលដៅបង្កើនភាពជឿទុកចិត្តបាននៃការអនុវត្តន៍ថវិកា ។ លើសពីនេះ ការបង្កើនការគោរពយ៉ាងហ្មឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ជាពិសេសចៀសវាងនូវការផ្ទេរ

ឥណទានថវិកាដែលនៅសល់ទៅឆ្នាំបន្ទាប់ ព្រមទាំងការចេញអាណត្តិបម្រុងទុក និង ការចេញអាណត្តិច្រើនហួសទៅបង្គរនៅធនាគារជាតិ ដែលជាប្រភពធ្វើឱ្យកើតមានឡើងនូវបំណុលសាច់ប្រាក់ថ្មីទៀត ។

*ទី៣-* បន្តពង្រឹងការគ្រប់គ្រងបំណុល ជាពិសេស ការកសាងទិន្នន័យ និង ការរៀបចំកម្មវិធីសងបំណុលអោយបានច្បាស់លាស់ និង ដោយផ្សាភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំថវិកា និង ការបន្តអនុវត្តយ៉ាងហ្មឹងម៉ាត់នូវការទិញតែឥណទានដែលបំរើអោយគោលនយោបាយអាទិភាព ។

*ទី៤-* បន្តបង្កើនចំណាយលើវិស័យសង្គមកិច្ច និង សេដ្ឋកិច្ច ជាពិសេសចំពោះបណ្តាវិស័យអាទិភាពដូចជា អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ និង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មាន ផ្លូវ- ថ្នល់ ស្ពាន និង ប្រព័ន្ធស្រោចស្រព ដែលជាអាទិភាពខ្ពស់ផុតរបស់រាជរដ្ឋាភិបាលនៅក្នុងនីតិកាលទី ៣ នៃរដ្ឋសភា ។

## III- និតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០០៧

### ក- ការគ្រោងចំណូលថវិកាឆ្នាំ ២០០៧

១៧- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬ ផលទុនដែលជាប្រភពចំណូលសារពើពន្ធ និង មិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និង បណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ÷

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
  - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
  - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
  - ការប៉ាន់ស្មានលើការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅពេលខាងមុខ
  - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និង ពិចារណាទៅលើអត្រាមូលដ្ឋានប្រមូលពន្ធ
  - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបាន ដោយសារការពង្រឹង និង កែលំអរដ្ឋបាល និង គោលនយោបាយពន្ធដារ គយ និង រដ្ឋាករ និង ការធ្វើទំនើបកម្មសារពើពន្ធ ។
- ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជាកិច្ចសន្យាជួលសេវាកម្ម និង ការពង្រឹង និង កែលំអការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាដើម ។ល។

ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិដែលសំរេចបាននៅក្នុងឆ្នាំកន្លងមក និងការ-អភិវឌ្ឍន៍សេដ្ឋកិច្ច ។ គ្រប់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ទាំងអស់ ត្រូវរៀបចំគំរោងចំណូលនេះហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុអោយបានត្រឹមថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវរៀបចំកិច្ចប្រជុំពិភាក្សាលើគំរោងចំណូលនេះជាមួយគ្រប់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង និង ធ្វើការបូកសរុបអោយបានចប់សព្វគ្រប់មុនការចាប់ផ្តើមចរចាថវិកានៅក្នុងខែសីហា ។

**ខ- ការគ្រោងចំណាយថវិកាឆ្នាំ ២០០៧**

១៨- ការរៀបចំគំរោងឥណទានចំណាយថវិកាត្រូវធ្វើឡើងជាពីរដំណាក់កាលគឺ ដំណាក់កាលទី ១ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកា (តាមគំរូដែលភ្ជាប់មកជាមួយស្រាប់) ដែលរួមមានការបញ្ជាក់ពី ទស្សនៈវិស័យ និង គោលបំណង ព្រមទាំងយុទ្ធសាស្ត្រ និង គោលដៅរយៈពេលមធ្យម (២០០៧-២០០៩) ដើម្បីបំរើអោយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង ដើម្បីបំរើអោយគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ព្រមទាំងកម្មវិធីសកម្មភាពចាំបាច់ដែលត្រូវអនុវត្តជាមួយនឹងតំរូវការថវិកាតាមប្រភេទ ។ ដំណាក់កាលទី ២ ត្រូវរៀបចំគណនាតំរូវការថវិកាដោយលំអិតទៅតាម ជំពូក គណនី និង អនុគណនី និង ទៅតាមនាយកដ្ឋាន និង អង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះអោយក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង (តាមគំរូដែលភ្ជាប់មកជាមួយស្រាប់) ដោយផ្អែកលើ តំរូវការជាក់ស្តែង និង ដោយផ្ទាល់ សំរាប់បំរើអោយការអនុវត្តន៍កម្មវិធីសកម្មភាពចាំបាច់ដែលត្រូវបានកំណត់ នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ រីឯការគណនាឥណទានចំណាយត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹង មុខសញ្ញាចំណាយ ដូចជា តារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតំលៃសំភារៈនៃការផ្គត់ផ្គង់ និង ត្រូវផ្អែកទៅតាមធម្មនិយាមចំណាយដែលបានកំណត់កន្លងមក ដូចជា ចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយ របស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សា សំរាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសំរាប់ការគ្រប់គ្រងកន្លងមក ។ ជាពិសេស តំរូវការចំណាយនីមួយៗ ត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និង មានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់ទៅតាមជំពូក គណនី និង អនុគណនី នីមួយៗ ។

**គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០០៧**

១៩- រាជរដ្ឋាភិបាលបានធ្វើការកំណត់នូវកញ្ចប់ថវិកា ដោយកំណត់គោលការណ៍ចំណាយទៅតាមប្រភេទ និង ជំពូក ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយសារពើពន្ធ និង ថវិកាសំរាប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ធ្វើជាមូលដ្ឋានក្នុងការរៀបចំគំរោងចំណាយលំអិតទៅតាមគណនី និង អនុគណនី និង ទៅតាមនាយកដ្ឋាន និង អង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះអោយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ដើម្បីបំរើអោយតំរូវការជាក់ស្តែងក្នុងការអនុវត្តន៍កម្មវិធីសកម្មភាពចាំបាច់ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ដូចជាឆ្នាំមុនៗដែរ ក្នុងរយៈពេលអនុវត្តថវិកានៃត្រីមាសទី ១ ឆ្នាំ ២០០៧ នេះ នឹងមិនមានការអនុញ្ញាតិឱ្យធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញ នៅតាមខេត្ត-ក្រុងទេ ។

២០- ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍នៃការកំណត់កញ្ចប់ថវិកា និង បណ្តាវិធានការដូចខាងក្រោម៖

ក- ចំណាយបៀវត្ស ត្រូវគ្រោងដោយបង្កើន ១៥% លើបៀវត្សមូលដ្ឋាន ទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និង តាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៦ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និង តាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និង

ហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និង មរណភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការ តម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែក ។ ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង មិនត្រូវគិតអតិផរណានៅក្នុងចំណាយបៀវត្សនេះទេ ។ ចំពោះបុគ្គលិកអណ្តែត និង ភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវស្នើសុំការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ជ្រើសរើស និង ប្រើប្រាស់ ។

ខ- ចំណាយដំណើរការរដ្ឋបាល ទិញសំភារៈ និង ការជួសជុលតូច ត្រូវគ្រោងដោយកាត់បន្ថយជារួម ៥% គឺត្រូវគ្រោងប្រកបដោយលក្ខណៈត្បិតត្បៀត និង សន្សំសំចៃបំផុត ជាពិសេស ចំពោះសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សំភារៈការិយាល័យ ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវ ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនអោយមានចំណាយលើសពីឥណទានថវិកា ដែលបានគ្រោងសំរាប់មុខសញ្ញានេះ និង ហាមដាច់ខាតមិនឱ្យមានការជំពាក់បំណុលដោយខ្ចីទំនិញ ឬ សេវាមកប្រើប្រាស់នៅក្រៅបរិបថនៃថវិកាទេ ។ កន្លងមកចំណាយសម្រាប់មុខសញ្ញាអគ្គិសនី ទូរស័ព្ទ ទឹក ប្រេងឥន្ធនៈ និង ការទទួលភ្ញៀវមានលក្ខណៈខ្ជះខ្ជាយ ។ ចំណាយសម្រាប់មុខសញ្ញាទាំងនេះចេះតែកើនឡើង ហើយការទូទាត់មិនបានទាន់ពេលវេលា ដែលនាំអោយមានបំណុលកកស្ទះពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហានេះ ចំពោះចំណាយ អគ្គិសនី ទូរស័ព្ទ និង ទឹក ត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង ស្ថាប័នទាំងអស់ ត្រូវសហការត្រួតពិនិត្យលើការប្រើប្រាស់បច្ចុប្បន្ន ដើម្បីរៀបចំយន្តការ និង ប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក អោយបានត្រឹមត្រូវ ម៉ត់ចត់ និង ប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីរកឃើញការលួចបន្តចរន្តអគ្គិសនី ទូរស័ព្ទ និង ទឹក ប្រើបាស់ផ្ទាល់ខ្លួនខុសមុខសញ្ញា របស់ក្រសួង ស្ថាប័នណាមួយ រដ្ឋមន្ត្រីក្រសួងនោះជាអ្នកទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និង ចំពោះមុខរដ្ឋសភា ។ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនទូរស័ព្ទ ត្រូវកាត់ផ្តាច់បណ្តាញលួចលាក់ទាំងនោះភ្លាម ហើយធ្វើរបាយការណ៍ជូនក្រសួងអាណាព្យាបាលបច្ចេកទេស និង ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និង ចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួង- ស្ថាប័នទាំងអស់ ត្រូវសហការគ្រោងឥណទានសំរាប់អគ្គិសនី ទូរស័ព្ទ និង ទឹក ប្រកបដោយភាពសន្សំសំចៃខ្ពស់ ដោយយកចំណាយជាក់ស្តែងពីឆ្នាំមុនធ្វើជាពិដាន ហើយកាត់បន្ថយចំណាយមុខសញ្ញានេះអោយចុះមកនៅក្នុងកំរិតមួយសមស្រប តាមការចាំបាច់ពិតប្រាកដរបស់ក្រសួងស្ថាប័ន ។

- ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និង ក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ ត្រូវផ្តល់វិក័យប័ត្រប្រចាំខែនីមួយៗ អោយបានមុនថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់វិក័យប័ត្រ និង រៀបចំទូទាត់អោយបានទៀងទាត់ និង ទាន់ពេលវេលារៀងរាល់ខែ ។ ហាមដាច់ខាតមិនអោយមានការពន្យាការទូទាត់លើមុខសញ្ញាចំណាយនេះ ដោយយកឥណទាននេះទៅប្រើប្រាស់លើមុខសញ្ញាផ្សេង ហើយផ្ទេរបន្ទុកនេះមកលើថវិការួមទេ ។

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្នើឡើងនូវវិធានការជាក់លាក់ ក្នុងការត្រួតពិនិត្យ និង គ្រប់គ្រង ការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និង ទឹក ដើម្បីដាក់ជូនប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ហើយដាក់ឱ្យគ្រប់ក្រសួង- ស្ថាប័នរបស់រាជរដ្ឋាភិបាលអនុវត្តឱ្យបានខ្ជាប់ខ្ជួន និង ហ្មឹងម៉ាត់បំផុត ។

- ក្នុងខណៈដែលប្រេងឥន្ធនៈកំពុងឡើងថ្លៃ គំរោងចំណាយប្រេងឥន្ធនៈសំរាប់ឆ្នាំ ២០០៧ ត្រូវកាត់បន្ថយចំនួន ៥% ធៀបនឹងឥណទានសំរាប់ចំណាយប្រេងឥន្ធនៈក្នុងឆ្នាំ ២០០៦ ដើម្បីអនុវត្តវិធានការសន្សំសំចៃថាមពលថ្នាក់ជាតិផង និង ដើម្បីត្រៀមបង្វែរចំណាយនេះ សំរាប់ចំណាយជាយថាហេតុនៃគ្រោះធម្មជាតិផង ។

គ- ចំពោះចំណាយសំរាប់ជំពូក គណនី និង អនុគណនីផ្សេងៗទៀត ត្រូវគ្រោងទៅតាមតំរូវការចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ក្នុងករណីតំរូវអោយមានកំណើន ដោយមានការវិភាគ និង ពន្យល់ច្បាស់លាស់ ក៏កំណើននោះមិនត្រូវអោយលើសពី ៥% នៃកញ្ចប់ថវិកាដែលបានអនុម័តឆ្នាំ ២០០៦ ដែរ ។ ចំពោះ ក្រសួងទាំង ៧ ដែលត្រូវចាប់ផ្តើមអនុវត្តសាកល្បងនូវថវិកាតាមកម្មវិធី ត្រូវញែកគំរោងចំណាយជាពីរផ្នែកសំរាប់ថវិកាតាមកម្មវិធី និង ថវិកាតាមមាតិកាទៅតាមគ្រប់ជំពូក គណនី និង អនុគណនី នីមួយៗ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវអញ្ជើញក្រសួងទាំង ៧ នេះ មកការពារគំរោងថវិកាតាមកម្មវិធីនេះដោយឡែក ។

ឃ- ឯកសារផែនការយុទ្ធសាស្ត្រថវិកា គំរោងចំណូល និង គំរោងចំណាយថវិកា ដែលក្រសួងស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺជាមូលដ្ឋានសំរាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំការពារថវិកា ដើម្បីការពារកញ្ចប់ថវិការបស់ខ្លួន ។ ដូច្នេះ ក្នុងករណីដែលក្រសួង- ស្ថាប័ន ឬ មន្ទីរជំនាញខេត្ត- ក្រុង ដែលមិនបានបំពេញ និង ផ្តល់ពត៌មានគ្រប់គ្រាន់សំរាប់ការប្រជុំការពារថវិកាទេនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុត្រូវជូនពត៌មានទៅអង្គភាពអោយបានទាន់ពេលវេលា ដើម្បីបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានសិទ្ធិយកមូលដ្ឋាននៃថវិកាឆ្នាំ ២០០៦ ហើយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូក គណនី និង អនុគណនីខាងលើ ដើម្បីកំណត់គំរោងថវិការបស់អង្គភាពនោះ ដើម្បីជាមូលដ្ឋានសំរាប់ការប្រជុំការពារថវិកា និង រៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុអោយបានទាន់ពេលវេលា ។

### ឃ- ការរៀបចំ និង ការវិភាគសំណើនានា

២១- ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (n-1) ឆ្នាំ ២០០៦ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម នស/រកម/១២០៥ /០៤០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០០៧ ឆ្នាំ (n) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន ។ ក្រសួង- ស្ថាប័ន ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និង ការណែនាំទាំងឡាយខាងលើនេះ សម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងបុណ្តាមូលហេតុដូចខាងក្រោម÷

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា៖

- ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង- ស្ថាប័ន ព្រមទាំងមន្ទីរជំនាញខេត្ត- ក្រុងមានការប្រែប្រួល ។
- ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ។
- ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និង ចំណាយរដ្ឋបាល ។ ល ។

២២- គម្រោងថវិការបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុង ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែម ត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយនូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបាន លុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៣- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួលអាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៤- បច្ចេកទេសវិភាគដទៃទៀតគឺ យកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាលសម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និង អត្ថប្រយោជន៍នៃចំណាយចាំបាច់មួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងនីមួយៗ ត្រូវតែបំពីទៅលើ:

- ទិសដៅរបស់ក្រសួង- ស្ថាប័ន និង មន្ទីរជំនាញខេត្ត- ក្រុងនីមួយៗ
- បណ្តាសកម្មភាពជាអាទិភាពរបស់ខ្លួនដែលបានកំណត់ច្បាស់លាស់
- កម្មវិធីដែលត្រូវចាប់ផ្តើមអនុវត្ត
- មធ្យោបាយដំណើរការ និង
- វិធានការនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់ ។

## IV- សេចក្តីសន្និដ្ឋាន

២៥- រាជរដ្ឋាភិបាលមានឆន្ទៈដាច់ខាតក្នុងការបន្តនូវកំណែទម្រង់គ្រប់វិស័យ ពិសេសគឺការពង្រឹងអភិបាលកិច្ចល្អក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ នៅក្នុងស្មារតីនេះ រាជរដ្ឋាភិបាលតម្រូវឱ្យគ្រប់ក្រសួងស្ថាប័នទាំងអស់ អនុវត្តយ៉ាងហ្មឺងម៉ាត់ និង ម៉ត់ចត់បំផុត នូវបទបញ្ញត្តិទាំងឡាយនៃអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ និង ប្រកាសស្តីពីការធ្វើវិសហមជ្ឈការលទ្ធកម្មសាធារណៈ ។ ដើម្បីធានាឱ្យបាននូវភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពក្នុងការអនុវត្តន៍

ចំណាយថវិកាជាតិ ជាពិសេស ដើម្បីជៀសវាងបញ្ហាកកស្ទះសាច់ប្រាក់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបន្តសហការជាមួយ ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីរៀបចំឱ្យបានត្រឹមត្រូវនូវផែនការលទ្ធកម្ម និង កម្មវិធីដេញថ្លៃជាសាធារណៈ និង ផែនការតម្រូវការសាច់ប្រាក់របស់ក្រសួង-ស្ថាប័ននីមួយៗ ដោយផ្អែកលើកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស សំរាប់ធានាទូទាត់កិច្ចសន្យាទាំងអស់នេះជាដំណាក់ៗ នៅក្នុងឆ្នាំថវិកានីមួយៗ ។

២៦- ពេលទទួលសារាចរណែនាំនេះ គ្រប់ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវរៀបចំជាបន្ទាន់នូវផែនការយុទ្ធសាស្ត្រថវិកា និង គំរោងចំណូល-ចំណាយថវិការបស់ខ្លួន សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ចំនួនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៦ ចំពោះគំរោងចំណូល ហើយត្រឹមថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៦ ចំពោះគំរោងចំណាយ ពីព្រោះការពិភាក្សាគំរោងចំណូលនឹងត្រូវធ្វើអោយបានមុនការពិភាក្សាគំរោងចំណាយដែលនឹងត្រូវចាប់ផ្តើមនៅថ្ងៃទី ០១ ដល់ ៣១ ខែសីហា ឆ្នាំ ២០០៦ នេះតទៅ ។ តួរលេខគំរោងចំណូល-ចំណាយថវិកា ត្រូវសរសេរ ជាលេខអន្តរជាតិ (1.2.3) ហើយឯកតាទាបបំផុតគិតត្រឹម 0.1 លានរៀល ។

២៧- ក្នុងការអនុវត្តន៍សារាចរណែនាំនេះ បើក្រសួង-ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

"*ដើម្បីជូនជ្រាប*"

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលខេត្ត-ក្រុង
- គ្រប់មន្ទីរជំនាញខេត្ត-ក្រុង

"*ដើម្បីអនុវត្ត*"

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.................

## គំរោងថវិកាឆ្នាំ ២០០៧
## គំរោងចំណាយថវិការយៈពេលមធ្យម

តារាង១ "ក"

| ប្រភេទចំណាយ | ២០០៤ | ២០០៥ | | ២០០៦ | | ២០០៧ | | ២០០៨ | | ២០០៩ | |
|---|---|---|---|---|---|---|---|---|---|---|---|
| | ជាក់ស្តែង | ជាក់ស្តែង | %កំណើន | ប៉ាន់ស្មាន | %កំណើន | គំរោង | %កំណើន | គំរោង | %កំណើន | គំរោង | %កំណើន |
| **សរុបរួមចំណាយថវិកា** (លានរៀល) | | | | | | | | | | | |
| ផលសរុបក្នុងស្រុក (លានរៀល) | 20.645.000 | 24.640.000 | 19,4% | 27.169.000 | 10,3% | 30.084.000 | 10,7% | | | | |
| % នៃផ.ស.ស | | | | | | | | | | | |
| **ក.ចំណាយចរន្ត** | | | | | | | | | | | |
| ជំពូក ៦០: ការទិញ | | | | | | | | | | | |
| ជំពូក ៦១: សេវាខាងក្រៅ | | | | | | | | | | | |
| ជំពូក ៦២: សេវាខាងក្រៅផ្សេងៗ | | | | | | | | | | | |
| ជំពូក ៦៤: បន្ទុកបុគលិក | | | | | | | | | | | |
| ជំពូក ៦៦: បន្ទុកហិរញ្ញវត្ថុ | | | | | | | | | | | |
| ជំពូក ៦៥: ឧបត្ថម្ភធន និង ជំនួយសង្គម | | | | | | | | | | | |
| ជំពូក ៦៣: ពន្ធ និង អាករ | | | | | | | | | | | |
| ជំពូក ៦៧: បន្ទុកពិសេស | | | | | | | | | | | |
| ជំពូក ៦៨: ទាយជ្ជទានអោយដល់រំលស់ អចលកម្ម | | | | | | | | | | | |
| ជំពូក ០៩: ចំណាយមិនបានគ្រោងទុក | | | | | | | | | | | |
| **ខ.ចំណាយមូលធន** | | | | | | | | | | | |
| ជំពូក ១៦: ការខ្ចីទាត់ប្រាក់ខ្ចី | | | | | | | | | | | |
| ជំពូក ២០: អចលកម្មអរូបី | | | | | | | | | | | |
| ជំពូក ២១: អចលកម្មរូបី | | | | | | | | | | | |
| ជំពូក ២៣: អចលកម្មកំពុងដំណើរការ | | | | | | | | | | | |
| ជំពូក ២៦: ភាគកម្ម និង សណាទេយ្យ ពាក់ព័ន្ធ | | | | | | | | | | | |
| ជំពូក ២៧: អចលកម្មហិរញ្ញវត្ថុផ្សេងៗ | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង..................

គំរោងថវិកាឆ្នាំ ២០០៧
ចំណូលថវិកាទូទៅរបស់រដ្ឋ

តារាង២ "ក"

( រដ្ឋបាលកណ្ដាល )

ឯកតា :លានរៀល

| ជំពូក | គណនី | អនុគណនី | តារាងមុខចំណូល (តាមតារាងមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៦ | | គំរោងឆ្នាំ ២០០៧ | | | បញ្ជាក់ពីមូលហេតុនៃការប្រែប្រួល |
|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | ចាំន់ស្មានអនុវត្ត | សរុប | រដ្ឋបាលកណ្ដាល | មន្ទីរជំនាញ | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

ថ្ងៃទី..............ខែ..................ឆ្នាំ ២០០៦
បានឃើញ និង ឯកភាព
ហត្ថលេខា និង ត្រារដ្ឋមន្ត្រី

ថ្ងៃទី..............ខែ................ឆ្នាំ ២០០៦
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.................

**គំរោងថវិកាឆ្នាំ ២០០៧**
**ចំណាយថវិកាទូទៅរបស់រដ្ឋ**

( រដ្ឋបាលកណ្តាល )

តារាងទី៣ "ត"

ឯកតា : លានរៀល

| ជំពូក | គណនី | អនុគណនី | តារាងមុខចំណាយ (តាមតារាងមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ២០០៦ | | | គំរោងឆ្នាំ ២០០៧ | | | បញ្ជាក់ពីមូលហេតុនៃការប្រែប្រួល និង តំរូវការឥណទាន |
|---|---|---|---|---|---|---|---|---|---|---|
| | | | | ច្បាប់ហិរញ្ញវត្ថុ | ឥណទានថ្មី | ប៉ាន់ស្មានអនុវត្ត | សរុប | រដ្ឋបាលកណ្តាល | មន្ទីរជំនាញ | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

ថ្ងៃទី..............ខែ................ឆ្នាំ ២០០៦
បានឃើញ និង ឯកភាព
ហត្ថលេខា និង ត្រារដ្ឋមន្ត្រី

ថ្ងៃទី..............ខែ................ឆ្នាំ ២០០៦
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង..................

## គំរោងថវិកាឆ្នាំ ២០០៧
## បញ្ជីសរុបនៃបុគ្គលិក បៀវត្ស និង ប្រាក់បំណាច់

តារាង៤ "ក"

| សូចនាករ | សរុបរួម | | មាយជ្ញទានដែលកត់ត្រាសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ | | | | | | | | | | | | បុគ្គលិកអណ្តែត | | បុគ្គលិកជាប់កិច្ចសន្យា | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | បៀវត្ស (លានរៀល) | ចំនួនបុគ្គលិក | បុគ្គ.អចិន្ត្រៃយ៍សរុប | | ប្រភេទ "ក" | | ប្រភេទ "ខ" | | ប្រភេទ "គ" | | ប្រភេទ "ឃ" | | ផ្សេងៗ | | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក |
| | | | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក | បៀវត្ស | ចំនួនបុគ្គលិក | | | | |
| សរុបរួម ( ១ + ២ ) | | | | | | | | | | | | | | | | | | |
| ១. ថ្នាក់កណ្តាល | | | | | | | | | | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | | | | | | | | |
| ២. មន្ទីរជំនាញ | | | | | | | | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង..................

គំរោងថវិកាឆ្នាំ ២០០៧

ការគ្រប់គ្រងអសន្ទរីមរដ្ឋបាល : ថ្លៃឈ្នួល ការរៀបចំ-ថែទាំ ទឹក និង អគ្គិសនី

តារាង៥ "ក"

ឯកតា :លានរៀល

| អង្គភាព | សរុប | សំរាប់ប្រើប្រាស់ក្នុងរដ្ឋបាល | | | | | សំរាប់ប្រើប្រាស់ក្នុងវាសនដ្ឋាន | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | គណនី ៦១៣ ថ្លៃឈ្នួល | ការថែទាំ និង ជួសជុល | | អនុគណនី ៦០៦២ ទឹក | អនុគណនី ៦០៦១ អគ្គិសនី | គណនី ៦១៣ ថ្លៃឈ្នួល | ការថែទាំ និង ជួសជុល | | អនុគណនី ៦០៦២ ទឹក | អនុគណនី ៦០៦១ អគ្គិសនី |
| | | | គណនី ៦១៥ | អនុគណនី ២១៣២ | | | | គណនី ៦១៥ | អនុគណនី ២១៣២ | | |
| សរុបរួម ( ១ + ២ ) | | | | | | | | | | | |
| ១. រដ្ឋបាលកណ្តាល | | | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| ២. មន្ទីរជំនាញ | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង..................

## គំរោងថវិកាឆ្នាំ ២០០៧

## ចលនវត្ថុ-សម្ភារៈ និង សម្ភារៈការិយាល័យ

តារាង៦ “ក”

ឯកតា :លានរៀល

| អង្គភាព | សរុប | ចលនវត្ថុ និង សំភារៈ | | | | ក្រដាសបោះពុម្ព និង គ្រឿងផ្គត់ផ្គង់ | |
|---|---|---|---|---|---|---|---|
| | | ការទិញ | | | ការថែទាំ | ក្រដាសបោះពុម្ព | សំភារៈការិយាល័យ |
| | | គណនី ៦០៥ | គណនី ២១៥ | គណនី ២១៨ | គណនី ៦១៥ | អនុគណនី ៦០២១ | អនុគណនី ៦០២១ |
| **សរុបរួម ( ១ + ២ )** | | | | | | | |
| **១. រដ្ឋបាលកណ្តាល** | | | | | | | |
| ខុទ្ទកាល័យ | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | |
| **២. មន្ទីរជំនាញ** | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង..................

គំរោងថវិកាឆ្នាំ ២០០៧

ជំពូក ៦០ ~ គណនី ៦០១ ~ អនុគណនី ៦០១៥

តារាង០៧ "ក"

| អង្គភាព | មធ្យោបាយ | | សរុប ទឹកប្រាក់ | ប្រេងឥន្ធនៈ (លានរៀល) | | | ប្រេងរំអិល (លានរៀល) | | |
|---|---|---|---|---|---|---|---|---|---|
| | ប្រភេទមធ្យោបាយ | សរុប | | សរុប | ប្រេងសាំង EA | ប្រេងម៉ាស៊ូត DO | សរុប | ម៉ាស៊ីនសាំង | ម៉ាស៊ីនម៉ាស៊ូត |
| សរុបរួម ( ១ + ២ ) | | | | | | | | | |
| ១. រដ្ឋបាលកណ្តាល | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | |
| ២. មន្ទីរជំនាញ | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង..................

គំរោងថវិកាឆ្នាំ ២០០៧

ចំណាយធ្វើនាត់សោហ៊ុយ : ជំពូក ៦២ - គណនី ៦២៤ និង ៦២៥

តារាង៨ "ក"

ឯកតា : លានរៀល

| អង្គភាព | សរុប | បេសកកម្មនៅក្នុងរង្វង់ខេត្ត-ក្រុង | | | បេសកកម្មឆ្លងខេត្ត-ក្រុង | | | បេសកកម្មក្រៅប្រទេស | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សោ.ដឹកជញ្ជូន | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ដឹកជញ្ជូន | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ដឹកជញ្ជូន | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ផ្សេងៗ |
| សរុបរួម ( ១ + ២ ) | | | | | | | | | | | |
| ១. រដ្ឋបាលកណ្តាល | | | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| នាយកដ្ឋាន / អង្គភាព......... | | | | | | | | | | | |
| ២. មន្ទីរជំនាញ | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង........................

**គំរោងថវិកាឆ្នាំ ២០០៧ តាមកម្មវិធី**

**ការគ្រោងចំណាយរយៈពេលមធ្យម**

តារាង ៥

ឯកតា :លានរៀល

| កម្មវិធីសកម្មភាព | ប្រភេទនៃកម្មវិធី/ សកម្មភាព (កំពុងដំណើរការ/ថ្មី) | ឆ្នាំ ២០០៦ | | | | ឆ្នាំ ២០០៧ | | | | ឆ្នាំ ២០០៨ | | | | ឆ្នាំ ២០០៩ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំណាយចរន្ត | | ចំណាយជាមូលធន | | ចំណាយចរន្ត | | ចំណាយជាមូលធន | | ចំណាយចរន្ត | | ចំណាយជាមូលធន | | ចំណាយចរន្ត | | ចំណាយជាមូលធន | |
| | | ឥណទាន | ប្រភព ឥណទាន | ឥណទាន | ប្រភព ឥណទាន | គំរោង ឥណទាន | ប្រភព ឥណទាន | គំរោង ឥណទាន | ប្រភព ឥណទាន | គំរោង ឥណទាន | ប្រភព ឥណទាន | គំរោង ឥណទាន | ប្រភព ឥណទាន | គំរោង ឥណទាន | ប្រភព ឥណទាន | គំរោង ឥណទាន | ប្រភព ឥណទាន |
| សរុបរួមរបស់ក្រសួង | | | | | | | | | | | | | | | | | |
| ក. កម្មវិធីទី១:................................ | | | | | | | | | | | | | | | | | |
| ក.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | | | | | | | |
| -សកម្មភាពទី១:........................ | | | | | | | | | | | | | | | | | |
| -សកម្មភាពទី២:........................ | | | | | | | | | | | | | | | | | |
| ................................................ | | | | | | | | | | | | | | | | | |
| ក.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | | | | | | | |
| ខ. កម្មវិធីទី២:................................ | | | | | | | | | | | | | | | | | |
| ខ.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | | | | | | | |
| -សកម្មភាពទី១:........................ | | | | | | | | | | | | | | | | | |
| -សកម្មភាពទី២:........................ | | | | | | | | | | | | | | | | | |
| ................................................ | | | | | | | | | | | | | | | | | |
| ខ.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | | | | | | | |
| គ. កម្មវិធីទី៣:................................ | | | | | | | | | | | | | | | | | |
| គ.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | | | | | | | |
| -សកម្មភាពទី១:........................ | | | | | | | | | | | | | | | | | |
| -សកម្មភាពទី២:........................ | | | | | | | | | | | | | | | | | |
| ................................................ | | | | | | | | | | | | | | | | | |
| គ.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង........................

**គំរោងថវិកាឆ្នាំ ២០០៧ តាមកម្មវិធី**

**ការគ្រោងចំណាយថវិកាឆ្នាំ ២០០៧ តាមជំពូក**

**តារាង ១០**

ឯកតា:លានរៀល

| កម្មវិធីសកម្មភាព | ប្រភេទនៃកម្មវិធី/ សកម្មភាព (កំពុងដំណើរការ/ថ្មី) | នាយកដ្ឋាន/ អង្គភាពប្រតិបត្តិ | ចំនួនមន្ត្រីបុគ្គលិក | សរុប ទឹកប្រាក់ | ចំណាយចរន្ត | | | | | | ចំណាយជាមូលធន | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ជំពូក ៦០ | ជំពូក ៦១ | ជំពូក ៦២ | ជំពូក ៦៤ | ............ | ជំពូក............ (សំរាប់ខ្ទង់ចំណាយដែលមិនអាចបំបែកបានតាមកម្មវិធី) | ជំពូក ១៦ | ជំពូក ២០ | ជំពូក ២១ | ............ | ជំពូក............ (សំរាប់ខ្ទង់ចំណាយដែលមិនអាចបំបែកបានតាមកម្មវិធី) |
| សរុបរួម | | | | | | | | | | | | | | | |
| ក. កម្មវិធីទី១:.................................... | | | | | | | | | | | | | | | |
| ក.១. អនុកម្មវិធីទី១:.......................... | | | | | | | | | | | | | | | |
| -សកម្មភាពទី១:.......................... | | | | | | | | | | | | | | | |
| -សកម្មភាពទី២:.......................... | | | | | | | | | | | | | | | |
| ................................................ | | | | | | | | | | | | | | | |
| ក.២. អនុកម្មវិធីទី២:.......................... | | | | | | | | | | | | | | | |
| ខ. កម្មវិធីទី២:.................................... | | | | | | | | | | | | | | | |
| ខ.១. អនុកម្មវិធីទី១:.......................... | | | | | | | | | | | | | | | |
| -សកម្មភាពទី១:.......................... | | | | | | | | | | | | | | | |
| -សកម្មភាពទី២:.......................... | | | | | | | | | | | | | | | |
| ................................................ | | | | | | | | | | | | | | | |
| ខ.២. អនុកម្មវិធីទី២:.......................... | | | | | | | | | | | | | | | |
| គ. កម្មវិធីទី៣:.................................... | | | | | | | | | | | | | | | |
| គ.១. អនុកម្មវិធីទី១:.......................... | | | | | | | | | | | | | | | |
| -សកម្មភាពទី១:.......................... | | | | | | | | | | | | | | | |
| -សកម្មភាពទី២:.......................... | | | | | | | | | | | | | | | |
| ................................................ | | | | | | | | | | | | | | | |
| គ.២. អនុកម្មវិធីទី២:.......................... | | | | | | | | | | | | | | | |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង........................

## គំរោងថវិកាឆ្នាំ ២០០៧ តាមកម្មវិធី

## ការកំណត់គោលបំណង លទ្ធផល និង សូចនាករនៃកម្មវិធី

តារាង ១១

| កម្មវិធីសកម្មភាព | ប្រភេទនៃកម្មវិធី/សកម្មភាព (កំពុងដំណើរការ/ថ្មី) | ឆ្នាំ ២០០៦ | | | | | ឆ្នាំ ២០០៧ | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | លទ្ធផលក្នុងឆ្នាំ (Output) | សូចនាករនៃលទ្ធផលក្នុងឆ្នាំ (Output Indicator) | | គោលបំណង (Objective) | លទ្ធផលចុងក្រោយ (Outcome) | លទ្ធផលក្នុងឆ្នាំ (Output) | សូចនាករនៃលទ្ធផលក្នុងឆ្នាំ (Output Indicator) | | គោលបំណង (Objective) | លទ្ធផលចុងក្រោយ (Outcome) |
| | | | ទិសដៅ (Target) | សំរេចបាន (Achievment) | | | | ទិសដៅ (Target) | បញ្ជាក់ពីមូលហេតុនៃការប្រែប្រួល | | |
| ក្រសួង | | | | | | | | | | | |
| ក. កម្មវិធីទី១:................................. | | | | | | | | | | | |
| ក.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | |
| -សកម្មភាពទី១:......................... | | | | | | | | | | | |
| -សកម្មភាពទី២:......................... | | | | | | | | | | | |
| .................................................. | | | | | | | | | | | |
| ក.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | |
| ខ. កម្មវិធីទី២:................................. | | | | | | | | | | | |
| ខ.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | |
| -សកម្មភាពទី១:......................... | | | | | | | | | | | |
| -សកម្មភាពទី២:......................... | | | | | | | | | | | |
| .................................................. | | | | | | | | | | | |
| ខ.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | |
| គ. កម្មវិធីទី៣:................................. | | | | | | | | | | | |
| គ.១. អនុកម្មវិធីទី១:...................... | | | | | | | | | | | |
| -សកម្មភាពទី១:......................... | | | | | | | | | | | |
| -សកម្មភាពទី២:......................... | | | | | | | | | | | |
| .................................................. | | | | | | | | | | | |
| គ.២. អនុកម្មវិធីទី២:...................... | | | | | | | | | | | |